# សំណួរដែលសួរញឹកញាប់

រដ្ឋបាលបោះឆ្នោតនៅសហរដ្ឋអាមេរិកមានវិមជ្ឈការខ្ពស់ដោយរដ្ឋនីមួយៗមានច្បាប់ផ្សេងៗគ្នាដែលគ្រប់គ្រងនីតិវិធីបោះឆ្នោត។
ច្បាប់សហព័ន្ធផ្តល់កំណត់ភាពអប្បបរមាមួយចំនួនដែលរដ្ឋនានាត្រូវតែប្រកាន់ខ្ជាប់។
ដូច្នេះប្រភពល្អបំផុតដើម្បីទទួលព័ត៌មានជាក់ស្តែងអំពីការចុះឈ្មោះ
និងព័ត៌មានបោះឆ្នោតគឺជាការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote
ដើម្បីតំណភ្ជាប់ទៅកាន់គេហទំព័របោះឆ្នោតនៅក្នុងតំបន់ឬដែនដីរបស់អ្នក
និងស្វែងរកទីតាំងបោះឆ្នោតក្នុងតំបន់របស់អ្នក។

សំណួរដែលសួរញឹកញាប់បន្ថែម

- សមាគមជាតិនៃនាយកដ្ឋានបោះឆ្នោតរដ្ឋ (National Association of State Election Directors) (NASED)
- សមាគមជាតិនៃលេខាធិការរបស់រដ្ឋ (National Association of Secretaries of State) (NASS)

## របៀបដែលការបោះឆ្នោតដំណើការ

### តើអ្នកណាជាអ្នករៀបចំបោះឆ្នោតនៅក្នុងរដ្ឋរបស់ខ្ញុំ?

រដ្ឋនីមួយៗមានមន្ត្រីរៀបចំការបោះឆ្នោត ដែលជាអ្នកគ្រប់គ្រង ឬផ្តល់ប្រឹក្សាលើការបោះឆ្នោតរដ្ឋ និងសហព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ការបោះឆ្នោតជាធម្មតាត្រូវបានគ្រប់គ្រងនៅថ្នាក់ខោនធី ក៏ប៉ុន្តែនៅក្នុងរដ្ឋមួយចំនួនទីក្រុង ឬសង្កាត់រៀបចំការបោះឆ្នោត។
គ្មានរដ្ឋពីរគ្រប់គ្រងការបោះឆ្នោតដូចគ្នាទេ ហើយក៏អាចមាននីតិវិធីផ្សេងៗនៅក្នុងរដ្ឋតែមួយ។
ការបោះឆ្នោតអាចរៀបចំដោយបុគ្គល ឬនាយកដ្ឋានតែមួយ ក្រុមប្រឹក្សាភិបាល ឬគណៈកម្មការរៀបចំការបោះឆ្នោត ឬការរួមបញ្ចូលគ្នានៃអង្គភាពពីរឬច្រើនជាង។

ការគ្រប់គ្រងការបោះឆ្នោតនៅអាមេរិកមានវិមជ្ឈការខ្ពស់។ មានយុត្តាធិការបោះឆ្នោតជាង 10,000 នៅសហរដ្ឋអាមេរិក យុត្តាធិការទាំងនេះមានទំហំផ្សេងពីគ្នា
ដោយទីក្រុងតូចបំផុតមានអ្នកចុះឈ្មោះត្រឹមតែពីរបីរយនាក់ប៉ុណ្ណោះ

ហើយជាយុត្តាធិការធំបំផុតនៅក្នុងប្រទេសដែលមានជាង 5 លាននាក់។ មន្ត្រីរៀបចំការបោះឆ្នោតក្នុងតំបន់ក៏ពឹងផ្អែកលើអ្នកធ្វើការនៅកន្លែងបោះឆ្នោតដែលបានទទួលការបណ្ដុះបណ្ដាល (ជាញឹកញាប់ទ្វេបក្សសម្ព័ន្ធនយោបាយ) ដែលជួយអ្នកបោះឆ្នោតក្នុងអំឡុងពេលបោះឆ្នោតមុនថ្ងៃកំណត់ និងនៅថ្ងៃបោះឆ្នោត។ តាមរយៈភ្នាក់ងារចាត់ចែងរបស់ខ្លួន EAC ផ្ដល់ការណែនាំ និងនីតិវិធីល្អបំផុត ដើម្បីជួយមន្ត្រីរៀបចំការបោះឆ្នោត ប៉ុន្តែ EAC មិនមានបទប្បញ្ញត្តិត្រួតត្រាលើការបោះឆ្នោតទេ។

ស្វែងយល់បន្ថែមអំពីអ្នកដែលរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក តាមរយៈចូលទៅកាន់គេហទំព័រ eac.gov/vote។

## តើបុគ្គលិកបោះឆ្នោតធ្វើអ្វីខ្លះ? តើខ្ញុំសុំស្ម័គ្រចិត្តដោយរបៀបណា?

បុគ្គលិកបោះឆ្នោតមានសារៈសំខាន់ណាស់ក្នុងការដំណើរការការបោះឆ្នោត។ បុគ្គលិកបោះឆ្នោតទទួលបន្ទុកបើកកន្លែងបោះឆ្នោតនៅព្រឹកថ្ងៃបោះឆ្នោត។ ពិនិត្យអ្នកបោះឆ្នោត និងចេញសន្លឹកឆ្នោត ជួយអ្នកបោះឆ្នោត ការអនុវត្តច្បាប់បោះឆ្នោត និងនីតិវិធី ការរៀបចំខ្សែសង្វាក់នៃការរក្សាសន្លឹកឆ្នោត ឧបករណ៍បោះឆ្នោតនិងសម្ភារៈ បិទការបោះឆ្នោត និងទូទាត់ចំនួនអ្នកបោះឆ្នោតដែលបានចុះឈ្មោះជាមួយនឹងចំនួនសន្លឹកឆ្នោតដែលបានបោះនៅទីតាំងរបស់ពួកគេ។

ជាធម្មតា បុគ្គលិកបោះឆ្នោតត្រូវបានបណ្ដុះបណ្ដាលដោយមន្ត្រីរៀបចំការបោះឆ្នោតក្នុងតំបន់ និងធ្វើការជាក្រុម (ជាញឹកញាប់ទ្វេបក្សសម្ព័ន្ធនយោបាយ)។ បុគ្គលិកបោះឆ្នោតស្បថថាគោរពច្បាប់បោះឆ្នោត និងការពារសន្តិសុខការបោះឆ្នោត។

សូមទាក់ទងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក ឬចូលទៅកាន់គេហទំព័រhelpamericavote.gov ដើម្បីស្វែងរកព័ត៌មានអំពីរបៀបចុះឈ្មោះជាអ្នកបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក។

## តើអ្នកណាអាចសង្កេតការណ៍បោះឆ្នោត?

អ្នកសង្កេតការណ៍បោះឆ្នោត ជួនកាលគេហៅថា "អ្នកឃ្លាំមើលការបោះឆ្នោត" គឺជាសាធារណៈជនដែលអាចសង្កេតមើលជំហានក្នុងដំណើរការបោះឆ្នោត។ រដ្ឋនីមួយៗមានច្បាប់ និងនីតិវិធីរៀងៗខ្លួនអំពីអ្នកណាដែលអាចចូលរួមសង្កេតការណ៍បោះឆ្នោត ប៉ុន្តែជាទូទៅ អ្នកសង្កេតការណ៍បោះឆ្នោតអាចជាសមាជិកនៃអង្គការដូចជា គណបក្សនយោបាយ ឬក្រុមមិនលម្អៀងតំណាងបេក្ខជន អ្នកសង្កេតការណ៍អន្តរជាតិ ក្រុមស្ទង់មតិពេលការបោះឆ្នោតរួច សិស្ស ឬស្ថាប័នពាក់ព័ន្ធរបស់សហព័ន្ធ និងរដ្ឋ។

តួនាទីរបស់អ្នកឃ្លាំមើលការបោះឆ្នោតគឺសង្កេត និងតាមដានការបោះឆ្នោតដោយមិនបំពានសិទ្ធិឯកជនរបស់អ្នកបោះឆ្នោត ឬរំខានដល់ការបោះឆ្នោត។ ច្បាប់ដែលគ្រប់គ្រងអ្នកឃ្លាំមើលការបោះឆ្នោតប្រែប្រួលតាមរដ្ឋ។ សូមទាក់ទងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នកឃ្លាំមើលការបោះឆ្នោតនៅក្នុងសហគមន៍របស់អ្នក។ ស្វែងយល់បន្ថែមអំពីការសង្កេតការបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នកដោយចូលទៅកាន់គេហទំព័រ eac.gov/vote។

## តើខ្ញុំរកលទ្ធផលបោះឆ្នោតនៅឯណា?

លទ្ធផលបឋមនៃការបោះឆ្នោតត្រូវបានបញ្ជូនដោយយុត្តាធិការក្នុងតំបន់ទៅកាន់មន្ត្រីបោះឆ្នោតរបស់រដ្ឋ បន្ទាប់ពីការបោះឆ្នោតបិទនៅថ្ងៃបោះឆ្នោត។ បន្ទាប់មក លទ្ធផលក្រៅផ្លូវការត្រូវបានបង្ហោះនៅលើគេហទំព័របោះឆ្នោតរបស់រដ្ឋ ហើយរាយការណ៍ទៅប្រព័ន្ធផ្សព្វផ្សាយ។ លទ្ធផលបឋមទាំងនោះអាចផ្លាស់ប្តូរក្រោយថ្ងៃបោះឆ្នោត ដោយសារមន្ត្រីរៀបចំការបោះឆ្នោតបន្តរាប់សន្លឹកឆ្នោតដែលមានសិទ្ធិទាំងអស់ រួមទាំងសន្លឹកឆ្នោតបណ្ដោះអាសន្ន សន្លឹកឆ្នោតអវត្តមាន និងតាមប្រៃសណីយ៍ និងសន្លឹកឆ្នោតដែលបោះដោយយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស។ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់ ទូទាត់ និងបញ្ជាក់នៅក្នុងអ្វីដែលហៅថា ផ្ទៀងផ្ទាត់សន្លឹកឆ្នោត បន្ទាប់មកលទ្ធផលចុងក្រោយត្រូវបានបង្ហោះ និងរាយការណ៍ វាអាចចំណាយពេលច្រើនថ្ងៃ ឬជួនកាលច្រើនសប្តាហ៍។

សូមចូលទៅកាន់គេហទំព័រ [eac.gov/vote](eac.gov/vote) សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក សម្រាប់ព័ត៌មានអំពីលទ្ធផលបោះឆ្នោតរដ្ឋ។

## ហេតុអ្វីលទ្ធផលបោះឆ្នោតប្រែប្រួលក្រោយពេលបោះឆ្នោត? តើលទ្ធផលបោះឆ្នោតចេញជាផ្លូវការពេលណា?

មន្ត្រីរៀបចំការបោះឆ្នោតរាប់សន្លឹកឆ្នោតឱ្យបានច្រើននៅយប់បោះឆ្នោតតាមដែលអាចធ្វើទៅបាន ប៉ុន្តែលទ្ធផលយប់បោះឆ្នោតនោះគឺមិនផ្លូវការ និងមិនទាន់បញ្ចប់។ រដ្ឋនីមួយៗមានច្បាប់ផ្សេងៗគ្នាសម្រាប់ពេលណាដែលបោះឆ្នោតជាសំបុត្រ បណ្ដោះអាសន្ន និងសន្លឹកឆ្នោតយោធា និងក្រៅប្រទេសអាចត្រូវបានរាប់។ ជាឧទាហរណ៍ រដ្ឋមួយចំនួនទាមទារសន្លឹកឆ្នោតតាមសំបុត្រទាំងអស់  ត្រូវទទួលនៅថ្ងៃបោះឆ្នោត។ រដ្ឋផ្សេងទៀតអនុញ្ញាតឱ្យរាប់សន្លឹកឆ្នោតតាមប្រៃសណីយ៍ ប្រសិនបើពួកគេត្រូវបានបោះតែមប្រៃសណីយ៍នៅថ្ងៃបោះឆ្នោត និងទទួលបានទាន់កាលបរិច្ឆេទជាក់លាក់មួយ។

នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានទទួល ការផ្ទៀងផ្ទាត់សន្លឹកឆ្នោតចាប់ផ្តើម។ ដំណើរការនេះជាធម្មតាពាក់ព័ន្ធនឹងការពិនិត្យចំនួនសន្លឹកឆ្នោត ដើម្បីកំណត់និងដោះស្រាយភាពមិនស្មើគ្នារវាងចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត។ រដ្ឋភាគច្រើនក៏ធ្វើសវនកម្ម ដើម្បីផ្ទៀងផ្ទាត់បន្ថែមទៀតថាចំនួនសន្លឹកឆ្នោតមានភាពត្រឹមត្រូវ។

នៅពេលដែលការផ្ទៀងផ្ទាត់ (និងនៅក្នុងរដ្ឋជាច្រើន ការធ្វើសវនកម្មវិញ) ត្រូវបានបញ្ចប់ លទ្ធផលបោះឆ្នោតត្រូវបានបញ្ជាក់ជាផ្លូវការ សម្រាប់ព័ត៌មានបន្ថែមអំពីលទ្ធផលបោះឆ្នោត សន្លឹកឆ្នោត និងការបញ្ជាក់ សូមចូលទៅកាន់គេហទំព័រ [https://www.eac.gov/election-officials/election-results-canvass-and-certification](https://www.eac.gov/election-officials/election-results-canvass-and-certification)

ការប្រណាំងបក្ស ឬការប្រកួតមួយចំនួនអាចត្រូវបានរាប់ឡើងវិញបន្ទាប់ពីដំណើរការបញ្ជាក់ ពីព្រោះវាជាការប្រណាំងយ៉ាងជិតស្និទ្ធឬ បេក្ខជន ឬក្រុមចំណាប់អារម្មណ៍ស្នើសុំឱ្យធ្វើដូច្នោះ។ ការរាប់ឡើងវិញខុសពីសវនកម្ម ដែលរាល់សន្លឹកឆ្នោតក្នុងការប្រកួត ឬក្រុមរងនៃការប្រកួតនៅក្នុងការបោះឆ្នោត ត្រូវបានរាប់ឡើងវិញ ហើយលទ្ធផលផ្លូវការនៃការបោះឆ្នោតអាចផ្លាស់ប្តូរជាលទ្ធផល។

## តើប្រព័ន្ធបោះឆ្នោតមានសុវត្ថិភាពទេ?

សុវត្ថិភាពនៃប្រព័ន្ធបោះឆ្នោតមានសារៈសំខាន់ចំពោះការបោះឆ្នោតដែលគួរឱ្យទុកចិត្ត។ គណៈកម្មការជំនួយការបោះឆ្នោត (EAC) បង្កើតគោលការណ៍ណែនាំប្រព័ន្ធបោះឆ្នោតដោយស្ម័គ្រចិត្ត (VVSG) ដែលកំណត់លក្ខណៈជាក់លាក់ និងតម្រូវការ រួមទាំងស្តង់ដារសុវត្ថិភាព និងសុចរិតភាព ដែលប្រព័ន្ធបោះឆ្នោតត្រូវតែបំពេញតាមដើម្បីទទួលបានវិញ្ញាបនប័ត្រ។ EAC ក៏ទទួលស្គាល់មន្ទីរពិសោធន៍បោះឆ្នោតដែលសាកល្បងប្រព័ន្ធបោះឆ្នោតតាមស្តង់ដារទាំងនេះផងដែរ។ ការចូលរួមក្នុងកម្មវិធីតេស្ត និងវិញ្ញាបនប័ត្រ EAC គឺដោយស្ម័គ្រចិត្ត ប៉ុន្តែរដ្ឋភាគច្រើនប្រើប្រាស់កម្មវិធីតេស្ត និងវិញ្ញាបនប័ត្ររបស់ EAC។ រដ្ឋក៏អាចជ្រើសរើសអនុវត្តវិធានការតឹងរ៉ឹងជាងសម្រាប់ប្រព័ន្ធបោះឆ្នោតផងដែរ។

គ្រប់រដ្ឋ និងយុត្តាធិការក្នុងមូលដ្ឋានប្រើប្រាស់នីតិវិធី និងឧបករណ៍បែបសុភវិនិច្ឆ័យ ដើម្បីការពារដំណើរការបោះឆ្នោត និងធានាថាលទ្ធផលបោះឆ្នោតរបស់ខ្លួនអាចជឿទុកចិត្តបាន។ ការអនុវត្តល្អបំផុតជាទូទៅរួមមាន ការប្រើសោ ការបិទតែមបញ្ឈប់ការរុករើ កាមេរ៉ាសុវត្ថិភាព ការធ្វើតេស្តប្រព័ន្ធមុន និងក្រោយការបោះឆ្នោត សវនកម្ម និងការគ្រប់គ្រងការចូលប្រើ និងសុវត្ថិភាពតាមអ៊ីនធឺណិត។ រដ្ឋនីមួយៗក៏មានមន្ត្រីរៀបចំការបោះឆ្នោត ដែលធានាថាច្បាប់ និងនីតិវិធីទាំងនេះត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង។

**វិធានការមួយចំនួនសម្រាប់ប្រព័ន្ធបោះឆ្នោត៖**

- ការទិញប្រព័ន្ធបោះឆ្នោតដែលបានសាកល្បង និងបញ្ជាក់
- កំណត់កម្មវិធីឧបករណ៍ទាំងអស់ដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងតំបន់
- ការធ្វើតេស្តភាពត្រឹមត្រូវនៃឧបករណ៍បោះឆ្នោតមុនពេលបោះឆ្នោត
- រៀបចំការបោះឆ្នោតជាមួយបុគ្គលិករៀបចំបោះឆ្នោតទ្វេបក្សសម្ព័ន្ធនយោបាយ និងអ្នកសង្កេតការណ៍
- ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតសរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតសរុប
- ធ្វើសវនកម្មសន្លឹកឆ្នោត ដើម្បីធានាថា ឧបករណ៍បោះឆ្នោតរាប់សន្លឹកឆ្នោតបានត្រឹមត្រូវ។
- ការកត់ត្រា និងផ្ទៀងផ្ទាត់ដោយសាក្សីយ៉ាងហោចណាស់ពីរនាក់ (តាមឧត្តមគតិទ្វេបក្សសម្ព័ន្ធនយោបាយ) ការផ្ទេរសន្លឹកឆ្នោត និងឧបករណ៍បោះឆ្នោតទាំងអស់ពីក្រុមមួយ ឬកន្លែងមួយទៅកន្លែងមួយទៀត។
- ការរក្សាឧបករណ៍គ្រប់គ្រងសន្តិសុខដែលការពារការចូលប្រើ

សន្លឹកឆ្នោតនៅតែរក្សាទុកដោយមន្ត្រីរៀបចំការបោះឆ្នោតក្នុងតំបន់ដែលដឹកនាំការបោះឆ្នោត។ សន្លឹកឆ្នោតក៏ត្រូវបានតម្រូវឱ្យរក្សាទុកដាក់ដោយសុវត្ថិភាពបន្ទាប់ពីការបោះឆ្នោត ដូច្នេះពួកគេអាចត្រូវបានគេពិនិត្យជាផ្នែកនៃសវនកម្ម ឬរាប់ឡើងវិញ។ សម្រាប់ព័ត៌មានបន្ថែមអំពីសុវត្ថិភាពការបោះឆ្នោត សូមចូលទៅកាន់គេហទំព័រ៖ https://www.eac.gov/voters/election-security.។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក សម្រាប់ព័ត៌មានអំពីសន្តិសុខការបោះឆ្នោតនៅក្នុងរដ្ឋរបស់អ្នក។

## តើខ្ញុំអាចជឿជាក់លើលទ្ធផលការបោះឆ្នោតបានទេ?

មានការដំណើរការ និងនីតិវិធីជាច្រើនត្រូវអនុវត្ត ដើម្បីធានាដល់សាធារណជនថាលទ្ធផលនៃការបោះឆ្នោតអាចជឿទុកចិត្តបាន។ មន្ត្រីរៀបចំការបោះឆ្នោតតែងតែទទួលការបណ្តុះបណ្តាលពីរដ្ឋនិងការណែនាំវិជ្ជាជីវៈក្នុងការគ្រប់គ្រងការបោះឆ្នោត។ ស្ទើរតែគ្រប់ផ្នែកនៃដំណើរការបោះឆ្នោតទាមទារឱ្យមានការចូលរួមពីមន្ត្រីដែលបានទទួលការបណ្តុះបណ្តាលពីពីររូប ឬច្រើននាក់ ដែលបានស្បថស្បថថានឹងគោរពច្បាប់បោះឆ្នោតទាំងអស់ និងការពារសន្តិសុខនៃការបោះឆ្នោត។ អ្នកសង្កេតការណ៍បោះឆ្នោត ដែលជួនកាលគេហៅថា "អ្នកឃ្លាំមើលការបោះឆ្នោត" ក៏អាចមានវត្តមានដើម្បីតាមដាន ឬសង្កេតការបោះឆ្នោតផងដែរ។

ម៉ាស៊ីនបោះឆ្នោត រួមទាំងម៉ាស៊ីនស្កេនសន្លឹកឆ្នោតត្រូវបានសាកល្បង និងបញ្ជាក់តាមស្តង់ដារភាពត្រឹមត្រូវជាក់លាក់។ រដ្ឋភាគច្រើនទាមទារការសាកល្បងតក្កវិជ្ជា និងភាពត្រឹមត្រូវលើប្រព័ន្ធបោះឆ្នោតមុនការបោះឆ្នោតនីមួយៗ។ បន្ថែមពីលើការធ្វើតេស្តមុនការបោះឆ្នោត រដ្ឋភាគច្រើនក៏ទាមទារឱ្យមានសវនកម្មបន្ទាប់ពីការបោះឆ្នោតនីមួយៗផងដែរ។ ក្នុងអំឡុងពេលសវនកម្ម មន្ត្រីរៀបចំការបោះឆ្នោតពិនិត្យមើលសន្លឹកឆ្នោតក្រដាស ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃការរាប់នៃម៉ាស៊ីន។ សវនកម្មធានាថាសន្លឹកឆ្នោតត្រូវបានរាប់តាមបំណងអ្នកបោះឆ្នោត ហើយថាលទ្ធផលនៃការបោះឆ្នោតអាចទុកចិត្តបាន។ ព័ត៌មានបន្ថែមអំពីសវនកម្មអាចរកបាននៅក្នុងរបាយការណ៍ EAC សវនកម្មការបោះឆ្នោតនៅទូទាំងសហរដ្ឋអាមេរិក។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក សម្រាប់ព័ត៌មានអំពីរបៀបដែលសន្លឹកឆ្នោតត្រូវបានរាប់នៅក្នុងរដ្ឋរបស់អ្នក។

## តើមន្ត្រីរៀបចំបោះឆ្នោតរារាំងអ្នកណាមិនឱ្យទៅបោះឆ្នោតពីរដងដោយរបៀបណា?

គោលការណ៍ជាមូលដ្ឋានមួយនៃលទ្ធិប្រជាធិបតេយ្យ គឺមនុស្សម្នាក់ៗមានការបោះឆ្នោតតែមួយប៉ុណ្ណោះ។ មន្ត្រីរៀបចំការបោះឆ្នោតចាត់វិធានការជាច្រើនដើម្បីធានាថាអ្នកបោះឆ្នោតគ្រាន់តែបោះឆ្នោតមួយសន្លឹកក្នុងការបោះឆ្នោតមួយ ឬប្រសិនបើអ្នកបោះឆ្នោតបោះច្រើនជាងមួយសន្លឹក (ឧទាហរណ៍ បោះឆ្នោតតាមសំបុត្រ ហើយព្យាយាមបោះឆ្នោតដោយផ្ទាល់នៅថ្ងៃបោះឆ្នោត) នោះមានតែសន្លឹកឆ្នោតមួយសន្លឹកប៉ុណ្ណោះត្រូវបានរាប់។ ដើម្បីធ្វើដូច្នេះបាន មន្ត្រីរៀបចំការបោះឆ្នោតមានទំនួលខុសត្រូវក្នុងការរក្សាបញ្ជីបោះឆ្នោតបច្ចុប្បន្ន និងឱ្យត្រឹមត្រូវ ហើយរដ្ឋជាច្រើនផ្ទៀងផ្ទាត់ចុះឈ្មោះ និងកំណត់ត្រាបោះឆ្នោតជាមួយរដ្ឋផ្សេងទៀត។ មន្ត្រីរៀបចំការបោះឆ្នោតរក្សាកំណត់ត្រាលម្អិតអំពីពេលណាដែលអ្នកបោះឆ្នោតត្រូវបានបោះឆ្នោត និងថាតើសន្លឹកឆ្នោតទាំងនោះត្រូវបានបោះឬអត់។

ប្រសិនបើសិទ្ធិបោះឆ្នោតមិនអាចបញ្ជាក់បានទេ (ឧ. អ្នកបោះឆ្នោតគ្មានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតទេ ព័ត៌មានអ្នកបោះឆ្នោតមិនពេញលេញ ឬមិនត្រឹមត្រូវ ឬអ្នកបោះឆ្នោតបានទទួលសន្លឹកឆ្នោតក្នុងសំបុត្ររួចហើយ និងត្រូវបានអនុញ្ញាតឱ្យបោះឆ្នោត) ពួកគេអាច ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតបណ្តោះអាសន្ន ឬសន្លឹកឆ្នោតដែលប្រើបានជាមិនខាន។

សន្លឹកឆ្នោតបណ្តោះអាសន្នត្រូវបានរក្សាទុកដាច់ដោយឡែកពីសន្លឹកឆ្នោតផ្សេងទៀត ហើយនឹងត្រូវបានដំណើរការ និងរាប់បានលុះត្រាតែមន្ត្រីរៀបចំការបោះឆ្នោតបានផ្ទៀងផ្ទាត់ថាអ្នកបោះឆ្នោតមានសិទ្ធិ និងមិនបានបោះឆ្នោតរួចហើយនៅក្នុងការបោះឆ្នោត។

នៅពេលអ្នកបោះឆ្នោតស្នើសុំសន្លឹកឆ្នោតតាមប្រៃសណីយ៍ មន្ត្រីរៀបចំការបោះឆ្នោតបញ្ជាក់ថា សំណើនេះត្រូវបានធ្វើឡើងដោយអ្នកបោះឆ្នោតមុនពេលចេញសន្លឹកឆ្នោត។ នៅពេលដែលសន្លឹកឆ្នោតត្រូវបានប្រគល់ទៅការិយាល័យបោះឆ្នោតវិញ មន្ត្រី (ជាញឹកញាប់ទ្វេបក្សសម្ព័ន្ធនយោបាយ) ផ្ទៀងផ្ទាត់ហត្ថលេខា ឬព័ត៌មានអត្តសញ្ញាណផ្សេងទៀតនៅលើស្រោមសំបុត្រសន្លឹកឆ្នោត ដើម្បីប្រាកដថាវាត្រូវបានបោះដោយអ្នកបោះឆ្នោត។ ប្រសិនបើព័ត៌មានចាំបាច់បាត់ ឬមិនពេញលេញ ឬប្រសិនបើហត្ថលេខាត្រូវបានទាមទារហើយវាមិនត្រូវគ្នានឹងមួយដែលមាននៅក្នុងឯកសារ សន្លឹកឆ្នោតនឹងមិនត្រូវបានរាប់បញ្ចូលនោះទេ។ ក្នុងករណីខ្លះ អ្នកបោះឆ្នោតអាចត្រូវបានជូនដំណឹង និងផ្តល់ឱកាសឱ្យកែបញ្ហា។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក សម្រាប់ព័ត៌មានអំពីរបៀបដែលសន្លឹកឆ្នោតត្រូវបានតាមដាន និងរាប់ក្នុងរដ្ឋរបស់អ្នក។

# ការចុះឈ្មោះអ្នកបោះឆ្នោត

## តើខ្ញុំត្រូវចុះឈ្មោះបោះឆ្នោតដោយរបៀបណា?

នៅក្នុងរដ្ឋទាំងអស់ក្រៅពី North Dakota អ្នកត្រូវបានចុះឈ្មោះដើម្បីចូលរួមក្នុងការបោះឆ្នោត។ សិទ្ធិចុះឈ្មោះបោះឆ្នោត អាចខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ ក៏ប៉ុន្តែជាទូទៅដើម្បីចុះឈ្មោះបោះឆ្នោតអ្នកត្រូវតែ៖

- ជាសញ្ជាតិអាមេរិក
- យ៉ាងហោចណាស់អាយុ 18 ឆ្នាំត្រឹមថ្ងៃបោះឆ្នោត
- បំពេញតាមតម្រូវការស្នាក់នៅមួយចំនួន

អ្នកអាចចុះឈ្មោះផ្ទាល់ តាមសំបុត្រ ឬ ក្នុងរដ្ឋជាច្រើនតាមអនឡាញ។ ប្រសិនបើលោកអ្នកមិនទាន់បានចុះឈ្មោះ ឬត្រូវធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នក សូមធ្វើមុនថ្ងៃផុតកំណត់ចុះឈ្មោះក្នុងរដ្ឋរបស់អ្នក។ រដ្ឋមួយចំនួន អនុញ្ញាតឱ្យអ្នកបោះឆ្នោតចុះឈ្មោះនៅថ្ងៃបោះឆ្នោត ប៉ុន្តែរដ្ឋផ្សេងទៀតមានថ្ងៃផុតកំណត់រហូតដល់ 30 ថ្ងៃមុនការបោះឆ្នោត។

រដ្ឋមួយចំនួនអាចអនុញ្ញាតឱ្យមនុស្សដែលមានអាយុក្រោម 18 ឆ្នាំចុះឈ្មោះជាមុនដើម្បីបោះឆ្នោត ដូច្នេះពួកគេអាចបោះឆ្នោតបានភ្លាមៗនៅពេលដែលពួកគេមានសិទ្ធិ។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote ដើម្បីតំណភ្ជាប់ទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីស្វែងយល់ព័ត៌មានបន្ថែមទាក់ទងនឹងតម្រូវការចុះឈ្មោះបោះឆ្នោត។ អ្នកក៏អាចនឹងទាញយកនឹងព្រិនពាក្យស្នើសុំចុះឈ្មោះអ្នកបោះឆ្នោតជាតិ។ ពាក្យនេះអាចប្រើបានដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋទាំងអស់ក្រៅពី រដ្ឋ North Dakota រដ្ឋ New Hampshire និង រដ្ឋ Wyoming ហើយមានបកប្រែជាភាសា 21 ផ្សេងៗ។ ដើម្បីទាញយកពាក្យមួយនេះសូមចូលទៅកាន់គេហទំព័រ https://www.eac.gov/voters/national-mail-voter-registration-form

## តើខ្ញុំប្តូរបក្សសម្ព័ន្ធនយោបាយរបស់ខ្ញុំដោយរបៀបណា?

ដំណើរការផ្លាស់ប្តូរបក្សសម្ព័ន្ធនយោបាយរបស់អ្នកជាធម្មតាដូចគ្នានឹងដំណើរការចុះឈ្មោះបោះឆ្នោតដែរ។

រដ្ឋមួយចំនួនតម្រូវឱ្យអ្នកប្រកាសបក្សសម្ព័ន្ធនយោបាយរបស់អ្នកនៅពេលចុះឈ្មោះ ខណៈដែលរដ្ឋខ្លះទៀតមិនតាមដានបក្សសម្ព័ន្ធនយោបាយរបស់អ្នក។ ប្រសិនបើរដ្ឋរបស់អ្នកតាមដានបក្សសម្ព័ន្ធនយោបាយ នឹងមានសំណួរមួយស្តីពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកដើម្បីប្រកាសពីបក្សសម្ព័ន្ធនយោបាយរបស់អ្នក។

រដ្ឋមួយចំនួនតម្រូវឱ្យអ្នកបោះឆ្នោតចុះឈ្មោះជាមួយសម្ព័ន្ធគណបក្ស ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតបឋម។ នៅក្នុងការបោះឆ្នោតទូទៅ (ដែលជាធម្មតាធ្វើឡើងក្នុងខែវិច្ឆិកា) អ្នកអាចបោះឆ្នោតឱ្យបេក្ខជនណាមួយដែលអ្នកចូលចិត្ត ដោយមិនគិតពីសម្ព័ន្ធគណបក្សនយោបាយ។ សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកសដើម្បីទទួលព័ត៌មានបន្ថែម។

## តើខ្ញុំធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកបោះឆ្នោតរបស់ខ្ញុំដោយរបៀបណា (ឈ្មោះ អាសយដ្ឋាន គណបក្សនយោបាយ។ល។)?

ដំណើរការធ្វើបច្ចុប្បន្នភាពការចុះឈ្មោះបោះឆ្នោតរបស់អ្នកជាធម្មតាដូចគ្នានឹងដំណើរការចុះឈ្មោះបោះឆ្នោតដែរ។

ធ្វើបច្ចុប្បន្នភាពព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ប្រសិនបើ៖

- អ្នកផ្លាស់លំនៅដ្ឋាន
- អ្នកប្តូរឈ្មោះរបស់អ្នក
- អ្នកចង់ផ្លាស់ប្តូរសម្ព័ន្ធគណបក្សនយោបាយរបស់អ្នក
- អ្នកមិនបានបោះឆ្នោតក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ

សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក ដើម្បីស្វែងរកជម្រើសសម្រាប់ការចុះឈ្មោះបោះឆ្នោត។ អ្នកក៏អាចដាក់ទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោតតាមសំបុត្រជាតិទៅការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក។ ទម្រង់បែបបទនេះអាចត្រូវបានប្រើដើម្បីចុះឈ្មោះឡើងវិញដើម្បីបោះឆ្នោតនៅគ្រប់រដ្ឋ លើកលែងតែ North Dakota, New Hampshire និង Wyoming ហើយវាមានជា 21 ភាសា។

### តើខ្ញុំពិនិត្យមើលព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់ខ្ញុំដោយរបៀបណា?

រដ្ឋនីមួយៗបង្កើតច្បាប់បោះឆ្នោតផ្ទាល់ខ្លួន រួមទាំងរបៀបបញ្ជាក់ការចុះឈ្មោះរបស់អ្នក។ ជាធម្មតា អ្នកអាចពិនិត្យមើលព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមអ៊ីនធឺណិត ឬដោយទាក់ទងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នក។ ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ វាជារឿងសំខាន់ក្នុងការត្រួតពិនិត្យដើម្បីធ្វើឱ្យប្រាកដថាព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកមានបច្ចុប្បន្នភាពនិងត្រឹមត្រូវ ជាពិសេសប្រសិនបើអ្នកបានផ្លាស់ប្តូរលំនៅដ្ឋាន ឬផ្លាស់ប្តូរឈ្មោះរបស់អ្នកនាពេលថ្មីៗនេះ។ សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីទទួលព័ត៌មានលម្អិតនិងទាន់សម័យបំផុតនៅកន្លែងដែលអ្នករស់នៅ។

### តើខ្ញុំលុបចោលការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំដោយរបៀបណា?

រដ្ឋ និងយុត្តាធិការក្នុងតំបន់មានជម្រើសផ្សេងៗ សម្រាប់អ្នកបោះឆ្នោតដែលមានបំណងលុបចោលការចុះឈ្មោះបោះឆ្នោតរបស់ពួកគេ។ ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតហើយចង់លុបចោល ឬដកការចុះឈ្មោះបោះឆ្នោតរបស់អ្នក ការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកអាចជួយអ្នកបាន។ សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីស្វែងរកបញ្ជីទីតាំងការិយាល័យបោះឆ្នោត។

### តើខ្ញុំរាយការណ៍អ្នកបោះឆ្នោតដែលបានចុះឈ្មោះ ដែលមិនរស់នៅតាមអាស័យដ្ឋានរបស់ខ្ញុំទៀតទេ ឬអ្នកបោះឆ្នោតដែលបានចុះឈ្មោះដែលបានស្លាប់ដោយរបៀបណា?

ប្រសិនបើអ្នកទទួលបានសំបុត្របោះឆ្នោតសម្រាប់នរណាម្នាក់ដែលលែងរស់នៅតាមអាសយដ្ឋានរបស់អ្នក ឬអ្នកដែលបានស្លាប់ សូមទាក់ទងការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកដើម្បីប្រាប់ពួកគេឱ្យដឹង។

ការរក្សាបញ្ជីឈ្មោះអ្នកបោះឆ្នោតឲ្យទាន់សម័យមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងការបោះឆ្នោត។ រដ្ឋទាំងអស់ចាត់វិធានការដើម្បីរក្សាបញ្ជីឈ្មោះអ្នកបោះឆ្នោតឱ្យមានបច្ចុប្បន្នភាព ប៉ុន្តែពេលខ្លះការិយាល័យបោះឆ្នោតមិនដឹងថាមាននរណាម្នាក់បានផ្លាស់ទីលំនៅដ្ឋាន ឬស្លាប់នោះទេ។ សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីអ្នកអាចស្វែងរកបញ្ជីទីតាំងការិយាល័យបោះឆ្នោត។

## របៀបបោះឆ្នោត

### តើខ្ញុំបោះឆ្នោតដោយផ្ទាល់នៅថ្ងៃបោះឆ្នោតដោយរបៀបណា?

រដ្ឋទាំងអស់ផ្តល់ជម្រើសបោះឆ្នោតដោយផ្ទាល់សម្រាប់អ្នកបោះឆ្នោតដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ នៅក្នុងរដ្ឋមួយចំនួន អ្នកបោះឆ្នោតត្រូវទៅទីតាំងជាក់លាក់មួយដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត

ខណៈពេលដែលរដ្ឋផ្សេងទៀតផ្តល់មណ្ឌលបោះឆ្នោតដែលអ្នកបោះឆ្នោតណាមួយនៅក្នុងយុត្តាធិការអាចបោះឆ្នោត។
សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីស្វែងរកទីតាំងបោះឆ្នោតរបស់អ្នក ម៉ោងបោះឆ្នោត និងប្រសិនបើអ្នកត្រូវការនាំយកអ្វីណាមួយ (ដូចជាអត្តសញ្ញាណប័ណ្ណ) ទៅជាមួយដើម្បីបោះឆ្នោត។

## តើខ្ញុំបោះឆ្នោតមុនដោយរបៀបណា?

រដ្ឋជាច្រើនអនុញ្ញាតឱ្យអ្នកបោះឆ្នោតទៅបោះឆ្នោតដោយផ្ទាល់នៅមុនថ្ងៃបោះឆ្នោត។ នៅក្នុងរដ្ឋមួយចំនួន ការបោះឆ្នោតមុនកាលកំណត់អាចតម្រូវឱ្យបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងតំបន់ ខណៈរដ្ឋខ្លះទៀត អ្នកអាចបោះឆ្នោតនៅទីតាំងបោះឆ្នោតដែលស្រដៀងនឹងការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។ ដើម្បីស្វែងយល់ថាបើរដ្ឋរបស់អ្នកផ្តល់ជូនការបោះឆ្នោតដោយផ្ទាល់នៅមុនថ្ងៃបោះឆ្នោត និងកន្លែងដែលអ្នកអាចបោះឆ្នោតបាន សូមចូលទៅកាន់គេហទំព័រ eac.gov/vote ហើយជ្រើសរើសរដ្ឋ ឬដែនដីរបស់អ្នក ហើយចុចលើតំណភ្ជាប់សម្រាប់ «អវត្តមាន/សំបុត្រ និង/ឬព័ត៍មានដើម្បីបោះឆ្នោតមុនថ្ងៃបោះឆ្នោត។»

## តើខ្ញុំបោះឆ្នោតតាមសំបុត្រដោយរបៀបណា?

រដ្ឋនីមួយៗមានច្បាប់រៀងៗខ្លួនពី អ្នកណាអាចបោះឆ្នោតតាមសំបុត្របាន។ រដ្ឋខ្លះទាមទារផ្តល់ហេតុផលមួយដើម្បីបោះឆ្នោតតាមសំបុត្រ ខ្លះអនុញ្ញាតឱ្យនរណាម្នាក់ស្នើសុំសន្លឹកឆ្នោតតាមសំបុត្រ ហើយរដ្ឋខ្លះទៀតផ្ញើសន្លឹកឆ្នោតទាំងអស់តាមសំបុត្រដោយស្វ័យប្រវត្តិ។ ឧទាហរណ៍នៃការផ្តល់ហេតុផលអាចរួមមានការកើតជំងឺ មានរបួស ពិការភាព លើសពីអាយុជាក់លាក់មួយ ការធ្វើដំណើរនៅខាងក្រៅសហគមន៍របស់អ្នកនៅថ្ងៃបោះឆ្នោត ការជានិស្សិតមហាវិទ្យាល័យនៅឆ្ងាយពីផ្ទះ ឬបម្រើក្នុងជួរយោធា។ ប្រសិនបើអ្នកស្នើសុំសន្លឹកឆ្នោតតាមសំបុត្រ ត្រូវប្រាកដថាបានពិនិត្យមើលកាលបរិច្ឆេទកំណត់ដើម្បីប្រគល់សន្លឹកឆ្នោតរបស់អ្នកវិញទាន់ពេលសម្រាប់វាត្រូវពួកគេបានរាប់ (រួមទាំងពេលវេលាប៉ាន់ស្មានសម្រាប់ការផ្ញើសំបុត្រ)។

ប្រសិនបើអ្នកបានទទួលសន្លឹកឆ្នោតអវត្តមាន ឬជាសំបុត្រ សូមអានដោយប្រុងប្រយ័ត្ននូវការណែនាំអំពីរបៀប និងពេលណាត្រូវប្រគល់សន្លឹកឆ្នោតតាមសំបុត្រវិញ។

- បំពេញព័ត៌មានទាំងអស់ដែលបានស្នើសុំនៅលើស្រោមសំបុត្រត្រឡប់មកវិញ។ រដ្ឋមួយចំនួនទាមទារឱ្យមានសារការី ឬហត្ថលេខាសាក្សីនៅលើស្រោមសំបុត្រ នៅពេលផ្ញើសន្លឹកឆ្នោតតាមសំបុត្រវិញ។
- លុះត្រាតែស្រោមសំបុត្រត្រឡប់មកវិញរបស់អ្នកនិយាយថាការប្រៃសណីយ៍ត្រូវបានបង់ប្រាក់ជាមុន ត្រូវប្រាកដថាមានតែមប្រៃសណីយ៍គ្រប់គ្រាន់នៅលើស្រោមសំបុត្រត្រឡប់មកវិញ មុនពេលផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមសំបុត្រ។

- តាមអនុសាសន៍របស់ USPS
  សូមផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញយ៉ាងហោចណាស់មួយសប្ដាហ៍មុនថ្ងៃកំណត់របស់រដ្ឋ ដើម្បីប្រាកដថាវាទៅដល់ការិយាល័យបោះឆ្នោតទាន់ពេល។
- អាស្រ័យលើច្បាប់ និងនីតិវិធីនៃយុត្តាធិការរបស់អ្នក
  អ្នកប្រហែលជាអាចផ្ញើសន្លឹកឆ្នោតតាមសំបុត្ររបស់អ្នកដោយផ្ទាល់ ឬដោយដាក់ក្នុងប្រអប់ផ្ញើក្នុងដែនសមត្ថកិច្ចរបស់អ្នក។

រដ្ឋជាច្រើនអនុញ្ញាតឱ្យអ្នកបោះឆ្នោតតាមដានស្ថានភាពនៃសន្លឹកឆ្នោតតាមសំបុត្ររបស់ពួកគេតាមអ៊ីនធឺណិត។

ចំណាំ៖ មន្ត្រីរៀបចំការបោះឆ្នោតយកចិត្តទុកដាក់លើភាពឯកជនរបស់អ្នក ហើយជំហានជាច្រើនត្រូវបានចាត់វិធានការដើម្បីធានាថាការបោះឆ្នោតរបស់អ្នកនៅតែមានភាពឯកជន។ មន្ត្រីរៀបចំការបោះឆ្នោតរក្សាកំណត់ត្រាថាតើអ្នកបោះឆ្នោតឬអត់ ប៉ុន្តែពួកគេមិនអាចប្រាប់ពីរបៀបដែលអ្នកបោះឆ្នោតបានទេ។

អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីការបោះឆ្នោតតាមប្រៃសណីយ៍ក្នុងរដ្ឋរបស់អ្នក រួមទាំងព័ត៌មានអំពីការតាមដានសន្លឹកឆ្នោតតាមប្រៃសណីយ៍ ប្រសិនបើត្រូវបានផ្តល់ជូននៅក្នុងរដ្ឋរបស់អ្នក នៅតាមគេហទំព័រ eac.gov/vote។

### ភាពងាយស្រួលក្នុងការចូលប្រើសម្រាប់ការបោះឆ្នោតតាមសំបុត្រ

សូមពិនិត្យជាមួយការិយាល័យបោះឆ្នោតរដ្ឋ ឬមូលដ្ឋានរបស់អ្នកសម្រាប់ព័ត៌មានអំពីជម្រើសដែលអាចចូលប្រើបានសម្រាប់ការស្នើសុំ ការសម្គាល់ និងការប្រគល់សន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែមអំពីភាពងាយស្រួលក្នុងការចូលប្រើបានក្នុងដំណើរការបោះឆ្នោតតាមប្រៃសណីយ៍ សូមមើល ការអនុវត្តល្អបំផុត៖ ភាពងាយស្រួលសម្រាប់ការបោះឆ្នោតតាមសំបុត្រ។

## តើប្រអប់ទម្លាក់សំបុត្រដំណើរការយ៉ាងដូចម្ដេច?

រដ្ឋមួយចំនួនអនុញ្ញាតឱ្យអ្នកបោះឆ្នោតប្រគល់សន្លឹកឆ្នោតតាមសំបុត្រ/សន្លឹកឆ្នោតអវត្តមានរបស់ពួកគេនៅក្នុងប្រអប់ទម្លាក់សំបុត្រសុវត្ថិភាព។ ប្រអប់ទម្លាក់សំបុត្រជួយកុំឱ្យត្រូវការតែមប្រៃសណីយ៍ត្រឡប់មកវិញ ដោយសារតែពួកគេអនុញ្ញាតឱ្យអ្នកបោះឆ្នោតប្រគល់សន្លឹកឆ្នោតរបស់ពួកគេដោយផ្ទាល់ទៅមន្ត្រីបោះឆ្នោត ជំនួសឱ្យការប្រើប្រាស់សេវាប្រៃសណីយ៍។ នេះអាចមានប្រយោជន៍សម្រាប់អ្នកបោះឆ្នោតដែលប្រហែលជាមិនមានពេលគ្រប់គ្រាន់ដើម្បីផ្ញើសន្លឹកឆ្នោតរបស់ពួកគេតាមរយៈសំបុត្រ។

ដើម្បីបោះឆ្នោតដោយប្រើប្រអប់ទម្លាក់៖

- ដាក់សន្លឹកឆ្នោតរបស់អ្នកនៅក្នុងស្រោមសំបុត្រត្រឡប់មកវិញ ហើយបំពេញព័ត៌មានទាំងអស់ដែលបានស្នើសុំនៅលើស្រោមសំបុត្រត្រឡប់មកវិញ។ រដ្ឋមួយចំនួនទាមទារឱ្យមានសារការី ឬហត្ថលេខាសាក្សីនៅលើស្រោមសំបុត្រ នៅពេលប្រគល់សន្លឹកឆ្នោតតាមសំបុត្រ។

- ដាក់សន្លឹកឆ្នោតរបស់អ្នកទៅក្នុងប្រអប់ទម្លាក់ក្នុងសហគមន៍របស់អ្នក។ (ចំណាំ៖ សូមប្រាកដថាប្រអប់ទម្លាក់ត្រូវបានសម្គាល់យ៉ាងច្បាស់ថាជារបស់ខោនធី ក្រុង ឬសង្កាត់ដែលអ្នករស់នៅ។)
- ប្រសិនបើប្រើប្រអប់ទម្លាក់វិញ សូមប្រាកដថាអ្នកប្រគល់សន្លឹកឆ្នោតតាមសំបុត្ររបស់អ្នកមិនយឺតជាងការបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

រដ្ឋនីមួយៗមានច្បាប់ និងតម្រូវការផ្ទាល់ខ្លួនសម្រាប់រក្សាសន្តិសុខប្រអប់ទម្លាក់។ ជាធម្មតា តម្រូវការទាំងនេះរួមមានសោ ឬវិធីបិទដាក់លាក់ ការឃ្លាំមើលតាមវីដេអូ និងខ្សែសង្វាក់នៃតម្រូវការក្នុងការរក្សាទុក។ រដ្ឋនិងតំបន់មួយចំនួនដាក់ប្រអប់ទម្លាក់តែក្នុងអគាររដ្ឋាភិបាល ឬទីតាំងសន្តិសុខដែលបានកំណត់នៅក្នុងយុត្តាធិការ។ មានតែមន្ត្រីរៀបចំការបោះឆ្នោត (ជាជាញឹកញាប់ទ្វេបក្សសម្ព័ន្ធនយោបាយ) ដែលត្រូវបានអនុញ្ញាតឱ្យប្រមូលសន្លឹកឆ្នោតនៅពេលដែលត្រូវបានដាក់ក្នុងប្រអប់ទម្លាក់។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែលមន្ត្រីបោះឆ្នោតធានាសន្តិសុខប្រអប់ទម្លាក់ សូមមើលការណែនាំដែលចេញដោយ EAC និងទីភ្នាក់ងារសន្តិសុខអ៊ីនធឺណិត និងហេដ្ឋារចនាសម្ព័ន្ធ (CISA) ស្តីពីការប្រើប្រាស់ និងធានាប្រអប់ទម្លាក់ប្រកបដោយប្រសិទ្ធភាព។

សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នកដើម្បីបញ្ជាក់បើប្រអប់ទម្លាក់មាននៅក្នុងតំបន់របស់អ្នកឬអត់។

## ខ្ញុំសញ្ជាតិអាមេរិក ប៉ុន្តែខ្ញុំរស់នៅប្រទេសផ្សេង។ តើខ្ញុំបោះឆ្នោតដោយរបៀបណា?

អ្នកបោះឆ្នោតដែលជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស និងក្រុមគ្រួសាររបស់ពួកគេមានបញ្ហាប្រឈមពិសេសក្នុងការបោះឆ្នោត។ ក្នុងចំណោមច្បាប់ការពារផ្សេងៗ ច្បាប់សហព័ន្ធតម្រូវឱ្យ (1) អ្នកបោះឆ្នោតដែលជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសអាចចុះឈ្មោះ និងទទួលសន្លឹកឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិច ហើយ (2) សន្លឹកឆ្នោតត្រូវបានផ្ញើតាមប្រៃសណីយ៍មិនលើសពី 45 ថ្ងៃមុនការបោះឆ្នោតសហព័ន្ធ។ រដ្ឋជាច្រើនមានការការពារបន្ថែមសម្រាប់អ្នកបោះឆ្នោតដែលជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសសម្រាប់ការបោះឆ្នោតទាំងអស់ មិនត្រឹមតែការបោះឆ្នោតសហព័ន្ធប៉ុណ្ណោះទេ

ច្បាប់រដ្ឋនឹងកំណត់តម្រូវការស្នាក់នៅសម្រាប់ពលរដ្ឋនៅក្រៅប្រទេសដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតរដ្ឋ និងសហព័ន្ធ។ កម្មវិធីជំនួយការបោះឆ្នោតសហព័ន្ធ (FVAP) មានធនធានសម្រាប់យោធា ក្រុមគ្រួសាររបស់ពួកគេ និងប្រជាពលរដ្ឋនៅក្រៅប្រទេសដែលមានបំណងចង់បោះឆ្នោត។ អ្នកបោះឆ្នោតអាចប្រើការណែនាំជំនួយការបោះឆ្នោតរបស់ FVAP ដើម្បីស្វែងរកព័ត៌មានបន្ថែមអំពីការបោះឆ្នោតនៅក្នុងរដ្ឋរបស់ពួកគេ និងរបៀបស្នើសុំ និងប្រគល់សន្លឹកឆ្នោតរបស់ពួកគេមកវិញ។

## តើខ្ញុំមានសិទ្ធិអ្វីខ្លះក្នុងនាមជាអ្នកបោះឆ្នោត?

រដ្ឋនីមួយៗមានច្បាប់រៀងៗខ្លួនដែលគ្រប់គ្រងពីរបៀបដែលការបោះឆ្នោតដំណើរការ ប៉ុន្តែមានច្បាប់សហព័ន្ធជាច្រើនដែលការពារសិទ្ធិបោះឆ្នោតសម្រាប់ពលរដ្ឋអាមេរិកដែលមានសិទ្ធិបោះឆ្នោត។ ច្បាប់ស្តីពីសិទ្ធិបោះឆ្នោតឆ្នាំ 1965 ហាមប្រាមការរើសអើង និងទាមទារឱ្យយុត្តាធិការអនុញ្ញាតឱ្យមានជំនួយក្នុងការបោះឆ្នោតក្នុងគ្រប់កាលៈទេសៈក្រៅពីស្ថានភាពមួយចំនួន ហើយច្បាប់ជួយពលរដ្ឋអាមេរិកបោះឆ្នោត (Help America Vote Act) បញ្ជាក់ឱ្យថា (1) អ្នកបោះឆ្នោតត្រូវតែអាចបោះឆ្នោតដោយឯកជន និងដោយឯករាជ្យ (2) ពួកគេត្រូវតែផ្តល់ឱ្យឱកាសក្នុងការផ្លាស់ប្តូរ ឬកែសន្លឹកឆ្នោតរបស់ពួកគេមុនពេលបោះ និង (3) អនុញ្ញាតឱ្យអ្នកបោះឆ្នោតបោះឆ្នោតបណ្តោះអាសន្ន ឬសន្លឹកឆ្នោតដែលប្រើបានជាមិនខាន។

## សិទ្ធិរបស់អ្នកនៅពេលបោះឆ្នោត

ច្បាប់បោះឆ្នោតសហព័ន្ធជួយការពារសិទ្ធិបោះឆ្នោតរបស់អ្នក និងដំណើរការបោះឆ្នោត។ ជាទូទៅ អ្នកបោះឆ្នោតមានសិទ្ធិ៖

- បោះឆ្នោតប្រសិនបើពួកគេនៅតែចាំឈរក្នុងជួររងចាំនៅពេលការបោះឆ្នោតបិទ
- សុំសន្លឹកឆ្នោតថ្មីមួយទៀតប្រសិនបើពួកគេធ្វើខុស
- សុំសន្លឹកឆ្នោតបណ្តោះអាសន្ន ប្រសិនបើពួកគេមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅទីតាំងបោះឆ្នោតរបស់ពួកគេ។
- សុំជំនួយភាសាពីអ្នកធ្វើការកន្លែងបោះឆ្នោតប្រសិនបើពួកគេត្រូវការជំនួយក្នុងការអាន ឬស្វែងយល់ពីរបៀបបោះឆ្នោត
- មិនត្រូវបំភិតបំភ័យ ឬយាយីក្នុងពេលបោះឆ្នោត

## ការបោះឆ្នោតសម្រាប់ជនពិការ

ច្បាប់សហព័ន្ធក៏ផ្តល់ការការពារដល់អ្នកបោះឆ្នោតដែលមានពិការភាពផងដែរ។ ជាពិសេស អ្នកបោះឆ្នោតដែលមានពិការភាពមានសិទ្ធិ៖

- បោះឆ្នោតដោយឯកជន និងឯករាជ្យ
- មានទីតាំងបោះឆ្នោតដែលអាចចូលប្រើបានជាមួយម៉ាស៊ីនបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព

អ្នកបោះឆ្នោតអាច៖

- ស្វែងរកជំនួយពីអ្នកធ្វើការកន្លែងបោះឆ្នោតនៅទីតាំងបោះឆ្នោតរបស់ពួកគេ ដែលបានទទួលការបណ្តុះបណ្តាលឱ្យប្រើប្រាស់ម៉ាស៊ីនបោះឆ្នោតដែលងាយចូលប្រើបាន ឬ
- នាំនរណាម្នាក់ឱ្យជួយបោះឆ្នោត

អ្នកបោះឆ្នោតអាចស្នើសុំព័ត៌មានអំពីជំនួយសម្រាប់ការបោះឆ្នោត អ្នកជំនួយការសម្រាប់ការបោះឆ្នោត និងនីតិវិធីដែលមានសម្រាប់បោះសន្លឹកឆ្នោតអវត្តមាន។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ eac.gov/vote ឬទាក់ទងគណៈកម្មការជំនួយការបោះឆ្នោតសហរដ្ឋអាមេរិក តាមរយៈលេខទូរសព្ទ 866-747-1471 ឬតាមរយៈអ៊ីមែល listen@eac.gov។ ព័ត៌មានអំពីច្បាប់ស្តីពីពិការភាពអាមេរិកមាននៅ ada.gov។

## ធនធានបន្ថែម

ប្រភពព័ត៌មានដ៏ល្អបំផុតសម្រាប់ការចុះឈ្មោះបោះឆ្នោត និងច្បាប់បោះឆ្នោតរបស់រដ្ឋរបស់អ្នក គឺការិយាល័យបោះឆ្នោតរដ្ឋ ឬតំបន់របស់អ្នក។ សូមចូលទៅកាន់គេហទំព័រ eac.gov/vote សម្រាប់តំណភ្ជាប់រហ័សទៅកាន់គេហទំព័របោះឆ្នោតរដ្ឋ ឬដែនដីរបស់អ្នក។

អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីច្បាប់សហព័ន្ធនៅលើគេហទំព័ររបស់ផ្នែកសិទ្ធិស៊ីវិលjustice.gov/crt/voting-section។

សម្រាប់បញ្ជីនៃច្បាប់ និងការការពារសិទ្ធិបោះឆ្នោតសហព័ន្ធ ក៏ដូចជាព័ត៌មានបោះឆ្នោតផ្សេងទៀត សូមចូលទៅកាន់គេហទំព័រ usa.gov/voting និង vote.gov។